III,C,Chp,40

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥.សសរ

## សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការ

## ដើម្បីរៀបចំសន្និសីទអាស៊ី-ក្បសួ ស្ដីពីចលនាភូមិមួយ ផលិតផលមួយ និងត្រៀមរៀបចំ

## សន្និសីទអាស៊ី-ក្បសួ ស្ដីពីចលនាភូមិមួយ ផលិតផលមួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល និង តាមសំណើរបស់ខេត្តអយតា ប្រទេសជប៉ុន

**ប្រការ១ :** បង្កើតគណៈកម្មការដើម្បីត្រៀមរៀបចំ សន្និសីទនិងកិច្ចប្រជុំកំពូលអាស៊ី-ក្បសួ និង សិក្ខាសាលាស្ដីពីចលនាភូមិមួយ ផលិតផលមួយ ដែលមានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១. ឯកឧត្ដម | សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្ដម | ទាវ ហួត | ប្រធាន OBSESS | អនុប្រធាន |
| ៣. ឯកឧត្ដម | សុខ ចិន្ដា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤. លោក | ណាកាណេ តេអ៊ីជី | តំណាងអង្គការ JETRO ប្រចាំនៅកម្ពុជា | ទីប្រឹក្សា |
| ៥. ឯកឧត្ដម | ត្រាក់ ថៃសៀង | អភិបាលរងក្រុងភ្នំពេញ | សមាជិក |
| ៦. ឯកឧត្ដម | ចាប ញ៉ាលីវុធ | អភិបាលខេត្តសៀមរាប | សមាជិក |
| ៧. ឯកឧត្ដម | សយ សុខា | អគ្គលេខាធិការ OBSESS | សមាជិក |
| ៨. បណ្ឌិត | ជា វ៉ាន់ដេត | អនុប្រធាននាយកដ្ឋាន ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

www.pheakdeylaw.com

៩. ឧកញ៉ា **ម៉ុង ឫទ្ធិ** ប្រធានក្រុមហ៊ុន ម៉ុង ឫទ្ធិ គ្រុប សមាជិក

១០. ឧកញ៉ា **អ៊ុំ ម៉ិនហួត** ប្រធានក្រុមហ៊ុន AZ Distribution សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចពិចារណានូវលទ្ធភាព នៃការអភិវឌ្ឍចលនាភូមិមួយ ផលិតផលមួយ និងរៀបចំសន្និសីទអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីចលនាភូមិមួយ ផលិតផលមួយ នាឆ្នាំ ២០០២ នៅភ្នំពេញ។

**ប្រការ៣ :** គណៈកម្មការនេះនឹងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ខេត្ត-ក្រុង សហគ្រាស ព្រមទាំងតំណាងខេត្តអូយតា ដើម្បីអភិវឌ្ឍចលនាភូមិមួយ ផលិតផលមួយ និងរៀបចំសន្និសីទអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីចលនាភូមិមួយ ផលិតផលមួយ អោយបានជោគជ័យ។

**ប្រការ៤ :** ដើម្បីរៀបចំការងារនេះអោយបានល្អនិងរលូន សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមរាល់កិច្ចប្រជុំក្នុងក្រុមការងារនៃតំណាងប្រទេសនិងតំបន់ ដែលគ្រោងចូលរួមសន្និសីទអាស៊ី-ប៉ាស៊ីហ្វិក " ស្តីពីចលនាភូមិមួយ ផលិតផលមួយ តាមកាលបរិច្ឆេទ។

**ប្រការ៥ :** គណៈកម្មការនេះនឹងបង្កើតលេខាធិការដ្ឋានមួយនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយ បណ្ឌិត **ឌិត ទីវ៉ាន់ដែត** ដើម្បីរៀបចំនិងទទួលនូវរាល់ឯកសារពាក់ព័ន្ធនឹងសន្និសីទនេះ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ប្រធានសហគ្រាស ព្រមទាំងសាមីខ្លួនដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com